# ករណីយកិច្ចការពារ ៖ ព័ត៌មានអំពីគោលការណ៍ និងជំហាននានាសំរាប់ការអនុវត្តន៍

ឯកសារនេះផ្តល់នូវព័ត៌មានទូទៅអំពីករណីយកិច្ចក្នុងការការពារ ដែលនេះគឺជាគោលការណ៍មួយ ដែលបានកើតមានឡើងកាលពីពេលដប់ឆ្នាំកន្លងមក ក្នុងគោលបំណងទប់ស្កាត់អំពើប្រល័យពូជសាសន៍ និង អំពើឃោរឃៅទ្រង់ទ្រាយធំដទៃៗទៀត ។ ឯកសារនេះត្រូវបានចែកជា ៥ ផ្នែក ដែលផ្តល់នូវព័ត៌មានអំពីៈ

១. តើអ្វីទៅជាករណីយកិច្ចការពារ? ព័ត៌មានជាមូលដ្ឋាន ។

២. សារតានៃគោលការណ៍នៃករណីយកិច្ចការពារ ។

៣. ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិចំពោះករណីយកិច្ចការពារ ៖ កិច្ចប្រជុំកំពូលថ្នាក់ពិភពលោក របស់អង្គការសហប្រជាជាតិ ឆ្នាំ ២០០៥ ។

៤. ការអនុវត្តន៍កម្មវិធីករណីយកិច្ចការពារ ។

៥. សំណួរ-ចំលើយទាក់ទងនឹងករណីយកិច្ចការពារ ។

## ១. តើអ្វីទៅជាករណីយកិច្ចការពារ? ព័ត៌មានជាមូលដ្ឋាន ៖

ករណីយកិច្ចការពារ គឺជាគោលការណ៍មួយនៅក្នុងទំនាក់ទំនងអន្តរជាតិ ដែលមានគោលបំណងទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ គោលការណ៍នេះចែងថា រដ្ឋនីមួយៗមានការទទួលខុសត្រូវក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន អោយជៀសផុតពីអំពើឧក្រិដ្ឋកម្ម ទាំងបួនប្រភេទនេះ ។ គោលការណ៍នេះក៏បានចែងផងដែរថា សហគមន៍អន្តរជាតិ មានការទទួលខុសត្រូវ ក្នុងការជួយដល់រដ្ឋក្នុងការបំពេញនូវភារៈកិច្ចនេះ ។ ក្នុងករណីដែលរដ្ឋមិនអាច ឬមិនមានឆន្ទៈក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន ទោះជាដោយសារហេតុផលអ្វីក៏ដោយ នៅពេលនោះសហគមន៍អន្តរជាតិមានការទទួលខុសត្រូវ ក្នុងការធ្វើអន្តរាគមន៍ដើម្បីសង្គ្រោះប្រជាពលរដ្ឋទាំងនោះ អោយរួចផុតពីអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅទ្រង់ទ្រាយធំផ្សេងៗទៀត ។ គោលការណ៍នេះ

ទទួលបានការគាំទ្រជាឯកច្ឆ័នពីសហគមន៍អន្តរជាតិ នៅក្នុងកិច្ចប្រជុំកំពូលពិភពលោករបស់អង្គការសហប្រជាជាតិឆ្នាំ ២០០៥ ។ នៅក្នុងកិច្ចប្រជុំកំពូលនេះ ប្រទេសនានា លើពិភពលោកបានសន្យាប្រកាន់យកនូវគោលការណ៍នៃករណីយកិច្ចការពារ ដើម្បីកុំអោយពិភពលោកជួបប្រទះនូវសោកនាដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍សាជាថ្មីទៀត ។

មានផ្នែកសំខាន់ៗ ៣ ដែលជាគ្រឹះសំរាប់ការអនុវត្តន៍ករណីយកិច្ចការពារ ។ ផ្នែកនីមួយៗមានសារៈសំខាន់ណាស់ ហើយផ្នែកទាំងបីត្រូវដំណើរការព្រមគ្នាដើម្បីទប់ស្កាត់អំពើឃោរឃៅធំៗទាំងនោះ ។ ផ្នែកសំខាន់ៗទាំងបីនោះរួមមានៈ

១. ករណីយកិច្ចរបស់រដ្ឋក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងពីការញុះញង់ដែលនាំអោយកើតមានឧក្រិដ្ឋកម្មទាំងនោះ។
២. ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិក្នុងការជួយដល់រដ្ឋនីមួយៗដើម្បីបំពេញនូវកាតួពកិច្ចទាំងនេះ ។
៣. ករណីយកិច្ចរបស់រដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ ក្នុងការឆ្លើយតបរួមគ្នាអោយបានទាន់ពេលវេលា និងអោយបានម៉ឺងម៉ាត់ នៅពេលដែលរដ្ឋខកខានមិនបានផ្តល់ការការពារបែបនេះ ។

## ២. សាវតានៃគោលការណ៍នៃករណីយកិច្ចការពារ

សតវត្សរ៍ទី ២០ គឺជា "សតវត្សរ៍នៃអំពើប្រល័យពូជសាសន៍" ។ ប្រជាជនរាប់លានលាននាក់នៅលើពិភពលោកត្រូវបានកាប់សំលាប់ ធ្វើទារុណកម្ម បង្អត់អាហារ និងបង្ខំអោយធ្វើការរហូតដល់ស្លាប់យ៉ាងឃោរឃៅជាទីបំផុត ដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានស្គាល់ថាជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ នៅក្នុងអំឡុងសង្គ្រាមលោកលើកទីមួយអំពើប្រល័យពូជសាសន៍មកលើជនជាតិអាមេនីបានឆក់យកជីវិតមនុស្សអស់ជាងមួយលាននាក់ ។ នៅក្នុងអំឡុងសង្គ្រាមលោកលើកទីពីរ របបណាស៊ីបានសំលាប់មនុស្សអស់ ១១ លាននាក់ រួមមានជនជាតិជីហ្វ ៦ លាន

នាក់ ព្រមទាំងអ្នកទោសសង្គ្រាម និងជនជាតិជីពស៊ី (ជាជនជាតិស្បែកសមួយក្រុមដែលមកពីប្រទេសឥណ្ឌា) រាប់លាននាក់ទៀត ។ នៅប្រទេសកម្ពុជា ប្រជាជនជិតពីរលាននាក់បានស្លាប់នៅក្រោមរបបខ្មែរក្រហម របស់ ប៉ុល ពត ។ នៅក្នុងប្រទេសជាច្រើនផ្សេងៗទៀត ក៏មានការកាប់សំលាប់យ៉ាងរង្គាលទៅលើប្រជាជនស៊ីវិលផងដែរ ដូចជានៅក្នុងប្រទេសហ្គាតេម៉ាឡា និងប្រទេសបង់ក្លាដែសជាដើម ។

នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ សហគមន៍អន្តរជាតិបាននិយាយថា "មិនត្រូវអោយមានម្តងទៀតឡើយ" ។ នៅពេលដែលអង្គការសហប្រជាជាតិត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៤៥ ពួកគេបាននិយាយថា សហគមន៍អន្តរជាតិនឹងមិនបណ្តែតបណ្តោយអោយមានការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអំពើឃោរឃៅយ៉ង់ឃ្នងសាជាថ្មីទៀតឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ មនុស្សជាតិមិនទាន់ធ្វើបានតាមការសន្យាទាំងនោះឡើយ ។ នៅទសវត្សឆ្នាំ ១៩៩០ ពិភពលោកទទួលរងនូវការរន្ធត់ជាថ្មីម្តងទៀតដោយសារអំពើប្រល័យពូជសាសន៍នៅប្រទេសបូស្នី និងរ៉្វាន់ដា ដែលក្នុងនោះបុរស ស្ត្រី និងកុមារជាង១លាននាក់ត្រូវបានសំលាប់ ហើយសហគមន៍អន្តរជាតិបានខកខានក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ទាំងនោះ ។

ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនចំពោះការបរាជ័យនេះ គឺការពិតដែលថាប្រទេសទាំងឡាយដែលជាសមាជិកអង្គការសហប្រជាជាតិមិនបានស្រុះស្រួលគ្នា ថាតើត្រូវធ្វើអន្តរាគមន៍ដើម្បីបញ្ឈប់ការសំលាប់រង្គាលនោះដែរឬយ៉ាងណា ។ តាមមូលដ្ឋានរបស់វា ការពិភាក្សានេះមានភាគីចំនួនពីរ ដោយភាគីម្ខាងៗមានអំណះអំណាងរៀងៗខ្លួន ក្នុងនោះភាគីម្ខាង គឺជាអ្នកដែលមើលឃើញពីភាពចាំបាច់ដែលសហគមន៍អន្តរជាតិត្រូវធ្វើអន្តរាគមន៍ប្រសិនបើមានអំពើប្រល័យពូជសាសន៍ ឬអំពើឃោរឃៅទ្រង់ទ្រាយធំកើតឡើង ("អន្តរាគមន៍មនុស្សធម៌") ហើយភាគីម្ខាងទៀតគឺជាអ្នកដែលប្រកាន់ខ្ជាប់នូវគំនិតបែបប្រពៃណី គឺការគោរព"អធិបតេយ្យភាពរដ្ឋ" ។ ការប្រកាន់យកនូវគំនិតអធិបតេយ្យភាពរដ្ឋតាមបែបប្រពៃណី ឬ បែប "Westphalian" នេះសំដៅដល់សិទ្ធិរបស់រដ្ឋមួយក្នុងការមានឯករាជ្យភាពផ្នែកនយោបាយ និងការមិនជ្រៀតជ្រែកផ្ទៃក្នុងពីរដ្ឋដទៃទៀត ។

ករណីយកិច្ចការពារ (ឬដែលតែងតែហៅកាត់ថា "RtoP") ត្រូវបានបង្កើតឡើងដោយសារតែការបរាជ័យទាំងនេះរបស់សហគមន៍អន្តរជាតិ ក្នុងការបញ្ឈប់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសបូស្នី និងរ៉្វាន់ដា ។ ករណីយកិច្ចការពារ គឺជាគោលការណ៍មួយដែលខិតខំប្រឹងប្រែងដើម្បីធានាថា សហគមន៍អន្តរជាតិ នឹងមិនបណ្តែតបណ្តោយអោយមានការខកខានម្តងទៀតឡើយ ក្នុងការចាត់វិធានការណ៍ទប់ស្កាត់នៅពេលដែលមានអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗបែបនេះកើតឡើង ។ គោលគំនិតដើមនៃករណីយកិច្ចការពារនេះត្រូវបានបង្កើតឡើងចេញពីការងាររបស់ Francis Deng ដែលជាអតីតអ្នកការទូតជនជាតិស៊ូដង់ ហើយដែលបានក្លាយជាអ្នកតំណាងពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកជនភៀសសឹក (IDPs) នៅក្នុងអំឡុងទសវត្សឆ្នាំ ១៩៩០ ហើយក៏ជាអ្នកជំនាញការនៅក្នុងផ្នែកនេះផងដែរ ។ Deng និងអ្នកដទៃទៀតបានអះអាងថា ទស្សនៈនៃ "អធិបតេយ្យភាពរដ្ឋ" មិនគួរផ្អែកទៅលើសិទ្ធិរបស់រដ្ឋនីមួយៗក្នុងការធ្វើអ្វីៗដែលខ្លួនចង់ធ្វើដោយពុំមានការជ្រៀតជ្រែកពីអន្តរជាតិនោះទេ ផ្ទុយទៅវិញអធិបតេយ្យភាពរដ្ឋគួរតែផ្អែកទៅលើការការពារប្រជាជនដែលរស់នៅក្នុងរដ្ឋរបស់ខ្លួន ។ និយាយអោយសាមញ្ញទៅ អធិបតេយ្យភាពរដ្ឋគប្បីចាប់ផ្តើមពីទស្សនទានដែលថា "អធិបតេយ្យភាពគឺជាករណីយកិច្ច" ។

គំនិតរបស់ Deng ដែលថា "អធិបតេយ្យភាពគឺជាករណីយកិច្ច" នោះ ក្រោយមកត្រូវបានគណៈកម្មការអន្តរជាតិដើម្បីអន្តរាគមន៍និងអធិបតេយ្យភាពរដ្ឋ (ICISS) ប្រើដើម្បីបង្កើតនូវគោលការណ៍នៃករណីយកិច្ចការពារ ។ គណៈកម្មការនេះត្រូវបានបង្កើតឡើងដើម្បីស្វែងរកដំណោះស្រាយទៅលើការជជែករវាងអ្នកដែលគាំទ្រអន្តរាគមន៍មនុស្សធម៌ និងអ្នកដែលគាំទ្រទស្សនៈបែបប្រពៃណីនៃអធិបតេយ្យភាពរដ្ឋ ។ គណៈកម្មការនេះបានចាប់ផ្តើមពីការងាររបស់របស់ Deng ដើម្បីអះអាងថា រដ្ឋមិនមែនគ្រាន់តែចាំទទួលផលប្រយោជន៍ពីសិទ្ធិ និងអភ័យឯកសិទ្ធិពីអធិតេយ្យភាពរបស់ខ្លួនប៉ុណ្ណោះនោះទេ ប៉ុន្តែរដ្ឋក៏ត្រូវតែទទួលយកនូវករណីយកិច្ចរបស់ខ្លួនក្នុងការការពារប្រជាពលរដ្ឋដែលរស់នៅក្នុងប្រទេសរបស់ខ្លួនផងដែរ ។

ប៉ុន្មានឆ្នាំក្រោយមក មានមនុស្ស និងអង្គការជាច្រើននៅលើពិភពលោកបានគាំទ្រគំនិតស្តីពីករណីយកិច្ចការពារ នេះ ។ ឧទាហរណ៍ មានការប្តេជ្ញាចិត្តរបស់អង្គការថ្នាក់តំបន់នានាក្នុងការការពារ ប្រជាពលរដ្ឋដែលរស់នៅក្នុងរដ្ឋរបស់ពួកគេ ។ ជាតួយ៉ាង ធម្មនុញ្ញរបស់សហភាពអាហ្រ្វិកឆ្នាំ ២០០២ មានមាត្រាដែល

អនុញ្ញាតអោយធ្វើអន្តរាគមន៍នៅក្នុងរដ្ឋដែលជាសមាជិកនៅពេលដែលមានឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកើតឡើង ។ លើសពីនេះ នៅក្នុងឆ្នាំ ២០០៧ គណៈកម្មការអាហ្វ្រិកស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន បានអនុម័តនូវសេចក្តីសំរេចមួយស្តីពីការពង្រឹងករណីយកិច្ចការពារនៅក្នុងទ្វីបអាហ្វ្រិក ។

នៅឆ្នាំ ២០០៥ អង្គការសហប្រជាជាតិបានរៀបចំកិច្ចប្រជុំកំពូលថ្នាក់ពិភពលោកមួយ ដែលមានការចូលរួមរបស់មេដឹកនាំជាច្រើនមកពីជុំវិញពិភពលោក ។ សមិទ្ធិផលសំខាន់បំផុតមួយក្នុងចំណោមសមិទ្ធិផលជាច្រើននៃកិច្ចប្រជុំកំពូលពិភពលោកនេះគឺ កិច្ចព្រមព្រៀងគ្នាជាឯកច្ឆ័នក្នុងរបស់មេដឹកនាំទាំងនោះ ដែលថារដ្ឋទាំងអស់មានករណីយកិច្ចការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ មេដឹកនាំទាំងអស់ក៏បានព្រមព្រៀងគ្នាថា ពួកគេបានត្រៀមខ្លួនដើម្បីចាត់វិធានការណ៍រួមគ្នា នៅពេលដែលរដ្ឋណាមួយខកខានក្នុងការការពារប្រជាជនរបស់ខ្លួនពីឧក្រិដ្ឋកម្មទាំងបួននេះ ។

ចាប់តាំងពីមានកិច្ចព្រមព្រៀងពីកិច្ចប្រជុំកំពូលថ្នាក់ពិភពលោកស្តីពី ករណីយកិច្ចការពារ ឆ្នាំ ២០០៥ នោះមក មានការរីកចំរើនជាច្រើនដែលសំរេចបាន ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនាពេលបច្ចុប្បន្ន គឺលោក បាន គីមូន បានបញ្ជាក់បន្ថែមអំពីករណីយកិច្ចការពារនេះ ដោយការចង្អុលបង្ហាញនូវផ្នែកសំខាន់ៗចំនួន ៣ សំរាប់ការអនុវត្តន៍គោលការណ៍នេះ ។ ផ្នែកសំខាន់ៗទាំងនោះគឺ :

១. ករណីយកិច្ចរបស់រដ្ឋក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងពីការញុះញង់ដែលនាំអោយមានអំពើទាំងនេះ ។
២. ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិក្នុងការជួយដល់រដ្ឋនីមួយៗដើម្បីបំពេញនូវកាតព្វកិច្ចទាំងនេះ ។
៣. ករណីយកិច្ចរបស់រដ្ឋដែលជាសមាជិកអង្គការសហប្រជាជាតិក្នុងការឆ្លើយតបរួមគ្នា អោយបានទាន់ពេលវេលានិងយ៉ាងម៉ឺងម៉ាត់នៅពេលដែលរដ្ឋណាមួយខកខានក្នុងការផ្តល់នូវការការពារបែបនេះ ។

ផ្នែកទាំងបីនេះមានអានុភាព និងភាពសំខាន់ស្មើគ្នា ។ តែទោះជាយ៉ាងណាក៏ដោយ ការទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅផ្សេងៗទៀត គឺជាប្រការសំខាន់បំផុតនៃគោលការណ៍នៃករណីយកិច្ចការពារ ។ សហគមន៍អន្តរជាតិសង្ឃឹមថា តាមរយៈកិច្ចសហប្រតិបត្តិការលើកករណីយកិច្ចការពារពិភពលោកនឹងមិនជួបប្រទះនូវអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬការបំបាត់ជាតិសាសន៍សាជាថ្មីឡើយ ។

*ការចាប់ផ្តើមនៃករណីយកិច្ចការពារ*

នៅឆ្នាំ ១៩៩៩ បន្ទាប់ពីឃើញអំពើប្រល័យពូជសាសន៍នៅប្រទេសរ្វាន់ដានិងបូស្នី មក អតីតអគ្គលេខា-ធិការអង្គការសហប្រជាជាតិ លោកកូហ្វី អាណាន់ បានអំពាវនាវអោយសហគមន៍អន្តរជាតិរិះរកនូវមធ្យោ-បាយដើម្បីដោះស្រាយភាពខ្វែងគំនិតគ្នារវាងអ្នកទាំងឡាយណាដែលគាំទ្រ "អន្តរាគមន៍មនុស្សធម៌" និងអ្នកដែលប្រកាន់ខ្ជាប់នូវអធិបតេយ្យភាពរដ្ឋតាមបែបបុរាណប្រពៃណីនោះ ។ លោក កូហ្វី អាណាន់ បានអំពាវនាវអោយមានមធ្យោបាយថ្មីដើម្បីដោះស្រាយចំណោទបញ្ហា ដែលថា តើពេលណាដែលជាពេលវេលាសមរម្យសំរាប់រដ្ឋក្នុងការចាត់វិធានការណ៍ដោយប្រើកំលាំង ជាពិសេសវិធានការណ៍ តាមផ្នែកយោធាដើម្បីប្រឆាំងនឹងរដ្ឋណាមួយ ក្នុងគោលបំណងដើម្បីការពារប្រជាពលរដ្ឋពីអំពីប្រល័យពូជសាសន៍ ឬអំពើឃោរឃៅផ្សេងៗទៀត ។

រដ្ឋាភិបាលនៃប្រទេសកាណាដាបានឆ្លើយតបចំពោះបញ្ហាប្រឈមនេះ ហើយបានបង្កើតគណៈកម្មការអន្តរជាតិដើម្បីអន្តរាគមន៍ និងអធិបតេយ្យភាពរដ្ឋ (Internatinal Commission on Intervention and State Sovereignty - ICISS) នៅឆ្នាំ ២០០០ ។ ក្រោមការដឹកនាំរបស់អ្នកជំនាញការអន្តរជាតិជាច្រើន ដូចជាលោក Gareth Evans និង Mohammed Sahnoun គណៈកម្មការនេះបានបង្កើតនូវគោលការណ៍នៃករណីយកិច្ចការពារ ដោយផ្អែកទៅលើការងារពីមុនៗរបស់ Francis Deng ស្តីពីទស្សនទានដែលថា "អធិបតេយ្យភាពគឺជាករណីយកិច្ច" ។ នៅក្នុងរបាយការណ៍របស់ខ្លួនក្នុងឆ្នាំ ២០០១ គណៈកម្មការនេះបានអះអាងថា រដ្ឋ

ទាំងអស់មានករណីយកិច្ចចាំបាច់ក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ របាយការណ៍នេះក៏បានលើកឡើងផងដែរថា សហគមន៍អន្តរជាតិមានករណីយកិច្ចក្នុងការជួយដល់រដ្ឋណាមួយក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីឧក្រិដ្ឋកម្មទាំងបួននេះ ។ ប្រសិនបើរដ្ឋណាមួយខកខានមិនបានការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឬអំពើឃោរឃៅធំៗដទៃទៀត នោះសហគមន៍អន្តរជាតិត្រូវទទួលខុសត្រូវការពារប្រជាពលរដ្ឋទាំងនេះ ។ ដើម្បីការពារប្រជាពលរដ្ឋទាំងនោះ សហគមន៍អន្តរជាតិគប្បីប្រើប្រាស់នូវវិធានការណ៍ផ្នែកការទូត សេដ្ឋកិច្ច និងវិធានការណ៍ច្បាប់ ហើយនៅទីបំផុតសំរាប់ស្ថានការដែលធ្ងន់ធ្ងរបំផុតអាចប្រើប្រាស់កំលាំងយោធា ។

របាយការណ៍របស់ ICISS បានកត់សំគាល់ពីការផ្លាស់ប្តូរមួយទៅលើរបៀបដែលសហគមន៍អន្តរជាតិឆ្លើយតបទៅនឹងវិបត្តិមនុស្សធម៌ ។ ករណីយកិច្ចការពារមានន័យថា បើទោះបីរដ្ឋាភិបាលនៃរដ្ឋនីមួយៗនៅតែជាតួអង្គចំបង និងសំខាន់ជាងគេក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនយ៉ាងណាក្តី ក៏ការទទួលខុសត្រូវនេះនឹងត្រូវផ្ទេរទៅអោយសហគមន៍អន្តរជាតិ នៅពេលដែលរដ្ឋនោះមិនអាច ឬមិនមានឆន្ទៈការពារប្រជាពលរដ្ឋរបស់ខ្លួននោះ ។ របៀបថ្មីនៃការពិនិត្យមើលទៅលើទំនាក់ទំនងរវាងអធិបតេយ្យភាពរដ្ឋ និងការការពារប្រជាពលរដ្ឋពីអំពើឃោរឃៅដែលកំពុងរីករាលដាលនេះ មានន័យថាគណៈកម្មការនេះ ត្រូវតែពិនិត្យមើលទស្សនទានទាំងនេះ ហើយដែលទស្សនទាននីមួយៗត្រូវបានលើកឡើងដោយសង្ខេបដូចខាងក្រោមនេះ :

*អធិបតេយ្យភាពរដ្ឋ និងការមិនធ្វើអន្តរាគមន៍*

"អធិបតេយ្យភាពរដ្ឋ" គឺជាទស្សនទានមួយដែលមានន័យជាសំខាន់ថាជាអត្តសញ្ញាណផ្លូវច្បាប់របស់រដ្ឋមួយនៅក្នុងច្បាប់អន្តរជាតិ ។ ទស្សនទាននេះគឺកើតចេញពីទស្សនទាន "Westphalian" ស្តីពីអធិបតេយ្យភាពរដ្ឋ ដែលត្រូវបានបង្កើតឡើងនៅក្នុងយុគសម័យទំនើបរបស់អឺរ៉ុបអស់រយៈពេលពីរបីរយឆ្នាំកន្លងមកហើយ ។

នេះគឺជាទស្សនទានដើម្បីធ្វើអោយមានរបៀបរៀបរយ និងស្ថេរភាពនៅក្នុងទំនាក់ទំនងអន្តរជាតិ ពីព្រោះនៅក្រោម ប្រព័ន្ធ Westphalian អធិបតេយ្យភាពរដ្ឋត្រូវបានចាត់ទុកមានភាពស្មើគ្នា ដោយមិនគិតពីទំហំ ឬទ្រព្យសម្បត្តិនោះទេ ។ គោលការណ៍នៃសមភាពផ្នែកអធិបតេយ្យភាពរបស់រដ្ឋបែបនេះ គឺជាគោលការណ៍គ្រឹះមួយនៃគោលការណ៍ជាច្រើនរបស់ធម្មនុញ្ញសហប្រជាជាតិ (សន្ធិសញ្ញានៃការបង្កើត អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៤៥) ។ រដ្ឋអធិបតេយ្យមានយុត្តាធិការ ឬការគ្រប់គ្រងទាំងស្រុងនៅក្នុងរង្វង់ព្រំដែននៃដែនដីរបស់ខ្លួន ។ នៅក្រោមប្រព័ន្ធនៃអធិបតេយ្យភាពរដ្ឋនេះ រដ្ឋដទៃទៀតមិនមានសិទ្ធិក្នុងការធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋអធិបតេយ្យដទៃទៀតនោះទេ ។

បើទោះបីអង្គការសហប្រជាជាតិប្រកាន់យកនូវគោលការណ៍អធិបតេយ្យភាពរដ្ឋបែបនេះយ៉ាងណាក្តី ក៏អង្គការសហប្រជាជាតិគឺជាអង្គការមួយដែលខិតខំប្តូរផ្តាច់ក្នុងការថែរក្សាសន្តិភាព និង សន្តិសុខអន្តរជាតិដែរ ។ គិតមកដល់ពាក់កណ្តាលសតវត្សរ៍ទី ២០ ជំលោះភាគច្រើនគឺជាជំលោះរវាងរដ្ឋ និងរដ្ឋ ប៉ុន្តែចាប់តាំងពីចុងសតវត្សរ៍ទី ២០ មក ចរិតលក្ខណៈនៃជំលោះបែបទំនើបមានការផ្លាស់ប្តូរ ហើយរហូតមកដល់បច្ចុប្បន្ននេះជំលោះភាគច្រើនគឺជាជំលោះផ្ទៃក្នុង ។ លើសពីនេះ សមាមាត្រនៃចំនួនប្រជាជនស៊ីវិលដែលត្រូវបានសំលាប់នៅក្នុងជំលោះនានា បានកើនឡើងយ៉ាងច្រើន ដោយកាលពីនៅដើមសតវត្សរ៍ទី ២០ មានមនុស្សម្នាក់ក្នុងចំណោម១០ នាក់ត្រូវបានសំលាប់ ប៉ុន្តែរហូតមកដល់ឆ្នាំ ២០០០ មានមនុស្សប្រហែល ៩ នាក់ក្នុងចំណោម ១០ នាក់ត្រូវបានសំលាប់ ។ ការផ្លាស់ប្តូរនូវចរិតលក្ខណៈនៃជំលោះបែបទំនើបនេះ បាននាំមកជាមួយនូវបញ្ហាប្រឈមមួយចេញពីអង្គការសហប្រជាជាតិ : ថាតើត្រូវសំរុះសំរួលយ៉ាងណានូវគោលការណ៍ដើមនៃអធិបតេយ្យភាពរដ្ឋ ជាមួយនឹងការទទួលខុសត្រូវដ៏សំខាន់ក្នុងការថែរក្សាសន្តិភាព និងសន្តិសុខ? ហើយដែលសំខាន់បំផុតនោះ ថាតើអង្គការសហប្រជាជនអាចការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗដទៃទៀតដោយរបៀបណា?

## *អធិបតេយ្យភាព ជាករណីយកិច្ច*

ដើម្បីជំនះភាពទ័លច្រកនេះ ICISS បានប្រើប្រាស់ការងារពីមុនរបស់ Deng ដែលថា "អធិបតេយ្យភាពជាករណីយកិច្ច" ដើម្បីអភិវឌ្ឍន៍គំនិតស្តីពីករណីយកិច្ចការពារ ។ នេះគឺជាការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងទំនាក់ទំនងអន្តរជាតិសំរាប់ហេតុផលជាច្រើន ។ ហេតុផលទីមួយ "អធិបតេយ្យភាពជាករណីយកិច្ច" មានន័យថា អាជ្ញាធររដ្ឋគឺជាអ្នកទទួលខុសត្រូវចំពោះការការពារសុវត្ថិភាព និងជីវិតរបស់ប្រជាពលរដ្ឋ និងក្នុងការលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ។ ហេតុផលទីពីរ "អធិបតេយ្យភាពជាករណីយកិច្ច" នេះមានន័យថាអាជ្ញាធរនយោបាយជាតិគឺជាអ្នកទទួលខុសត្រូវចំពោះប្រជាពលរដ្ឋរបស់ខ្លួនផង និងចំពោះសហគមន៍អន្តរជាតិ តាមរយៈអង្គការសហប្រជាជាតិផង ។ ហេតុផលទីបី "អធិបតេយ្យភាពជាករណីយកិច្ច" មានន័យថា ភ្នាក់ងាររដ្ឋគឺជាអ្នកទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។

## *យុគសម័យថ្មី : ករណីយកិច្ចបង្ការ ចាត់វិធានការណ៍ និងស្តារឡើងវិញ*

ករណីយកិច្ចការពារបានក្លាយជាមធ្យោបាយមួយក្នុងការបង្រួបបង្រួមនូវទស្សនទានទាំងពីរ ពោលគឺអធិបតេយ្យភាពរដ្ឋ និងការការពារប្រជាជនក្នុងលក្ខណៈមនុស្សធម៌ពីវិបត្តិផ្សេងៗ ។ របាយការណ៍របស់ ICISS បានបង្ហាញ ពីរបៀបបង្រួបបង្រួមទស្សនទានទាំងពីរនេះ ហើយលើសពីនេះទៀតរបាយការណ៍នេះបានអះអាងថា គោលការណ៍នៃករណីយកិច្ចការពារ គប្បីរួមបញ្ចូលនូវករណីយកិច្ចបីដូចខាងក្រោមនេះ :

១. ករណីយកិច្ចក្នុងការបង្ការមិនអោយមានអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗដទៃទៀត ។ នេះគឺជាការទទួលខុសត្រូវទាំងរបស់រដ្ឋនីមួយៗផង និងរបស់សហគមន៍អន្តរជាតិផង ក្នុងការដោះស្រាយនូវបុព្វហេតុនៃ ជំលោះ ដូចជា ភាពក្រីក្រ បញ្ហានៃការបែងចែកធនធាន និងការគាបសង្កត់ផ្នែកសេដ្ឋកិច្ច នយោបាយ និងសង្គម ជាដើម ។

២. ករណីយកិច្ចក្នុងការចាត់វិធានការណ៍ ឬឆ្លើយតបទៅនឹងស្ថានភាពទាំងឡាយដែលអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានចាប់ផ្តើមរួចហើយ ឬទំនងជានឹងកើតឡើង ។

៣. ករណីយកិច្ចក្នុងការស្តារឡើងវិញ ក្រោយពេលមានអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗផ្សេងទៀតកើតឡើង ។ នេះគឺជាការទទួលខុសត្រូវរបស់រដ្ឋនីមួយៗ និងសហគមន៍អន្តរជាតិក្នុងការផ្តល់ជំនួយដល់ សង្គមទាំងឡាយណាដែលទទួលរងនូវអំពើឃោរឃៅធំៗ ដើម្បីស្តារ និងកសាង និងផ្សះផ្សារឡើងវិញបន្ទាប់ពីមានជំលោះ ។

ក្តីសង្ឃឹមគឺនៅត្រង់ថា តាមរយៈការធ្វើអោយករណីយកិច្ចការពារ មានការទទួលខុសត្រូវទាំងបីនេះ សហគមន៍អន្តរជាតិនឹង បានត្រៀមខ្លួនជាស្រេចដើម្បីឆ្លើយតបទៅនឹងគ្រប់ដំណាក់កាល ទាំងអស់នៃអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅ ធំៗដទៃទៀត ។ នោះមានន័យថា គឺជាការសង្ឃឹមដែលថាសហគមន៍អន្តរជាតិនឹងរៀបចំខ្លួនរួចជាស្រេចដើម្បីបង្ការ ចាត់វិធានការណ៍ និងកសាងឡើងវិញ បន្ទាប់ពីមានការរំលោភបំពានសិទ្ធិ ធ្ងន់ធ្ងរបែបនេះកើតឡើង ។

## ៣. ការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិចំពោះករណីយកិច្ចការពារ ៈ កិច្ចប្រជុំកំពូលថ្នាក់ពិភពលោករបស់អង្គការសហប្រជាជាតិ ឆ្នាំ 2005

បន្ទាប់ពីរបាយការណ៍របស់ ICISS បានចេញផ្សាយនៅចុងឆ្នាំ ២០០១ មានការគាំទ្រចំពោះករណីយកិច្ចការពារកាន់តែច្រើនឡើងៗ ។ កាលនោះវាគឺជារយៈពេលដ៏លំបាកមួយនៅក្នុងប្រវត្តិសាស្រ្តនៃទំនាក់ទំនងអន្តរជាតិ ដោយ សារតែមានការវាយប្រហារភេរវកម្មនៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០១ និងការឈ្លានពានប្រទេសអ៊ីរ៉ាក់ និងអាហ្គានីស្ថានក្នុងពេលបន្តបន្ទាប់មកទៀត ។ តែទោះជាយ៉ាងណាក៏ដោយ រយៈពេលពីរបីឆ្នាំក្រោយមកទៀត គោលការណ៍នេះត្រូវបានលើកយកមកពិភាក្សា និងមានការគាំទ្រកាន់តែច្រើនឡើងៗ ។ មានការវិវត្តន៍សំខាន់ៗជាច្រើនទាក់ទងនឹងការគាំទ្រករណីយកិច្ចការពារនេះកាលក្នុងអំឡុងពេលនេះ ពោលគឺទាំងក្នុងចំណោមរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល ។ ជាតួយ៉ាងដូចជា រដ្ឋាភិបាលនៃប្រទេសកាណាដាបានជួយរៀបចំសិក្ខាសាលា និងកិច្ចពិភាក្សានានា ស្តីពីករណីយកិច្ចការពារនេះជាមួយនឹងអង្គការមិនមែនរដ្ឋា-

ភិបាល និងក្រុមសង្គមស៊ីវិលជាច្រើន ដែលនាំអោយអង្គការទាំងនេះជាច្រើនបានគាំទ្រគោលការណ៍នេះ ។ បន្ទាប់មក ការបោះជំហានទៅមុខដ៏ធំមួយទៀតគឺថា អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ គឺលោក កូហ្វី អាណាន់ គឺជាអ្នកតស៊ូមតិអោយមានករណីយកិច្ចការពារនេះ ។ នៅក្នុងរបាយការណ៍ផ្ទាល់ខ្លួនរបស់គាត់ស្តីអំពីកំណែទំរង់អង្គការសហប្រជាជាតិកាលពីនៅដើមឆ្នាំ ២០០៥ ដែលមានចំណងជើងថា *In Larger Freedom* លោកកូហ្វី អាណាន់ បានសង្កត់ធ្ងន់ទៅលើការទាមទារអោយប្រកាន់យក និងអនុវត្តនូវគោលការណ៍នេះ ។

អ្នកគាំទ្រទាំងអស់នេះ រួមជាមួយនឹងមនុស្សកាន់តែច្រើនឡើងៗដែលធ្វើការដើម្បីជំរុញអោយមានការគាំទ្រចំពោះករណីយកិច្ចការពារនេះ បាននាំអោយមានកិច្ចព្រមព្រៀងមួយក្នុងចំណោមសហគមន៍អន្តរជាតិដើម្បីការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗដទៃទៀត ។ កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំកំពូលពិភពលោក ។ កិច្ចប្រជុំកំពូលនេះត្រូវបានប្រារព្ធធ្វើនៅខែកញ្ញា ឆ្នាំ ២០០៥ ដែលកាលនោះមេដឹកនាំលើពិភពលោកបានមកជួបជុំគ្នានៅក្នុងទីក្រុងញូវយ៉ក ដើម្បីប្រារព្ធពិធីខួបលើកទី ៦០ នៃអង្គការសហប្រជាជាតិ និងដើម្បីពិភាក្សាអំពីកំណែទំរង់ដែលបានស្នើឡើងដោយលោក កូហ្វី អាណាន់ ។ នៅចុងបញ្ចប់នៃកិច្ចប្រជុំកំពូលនេះ សហគមន៍អន្តរជាតិបានអនុម័តលើគោលការណ៍នៃករណីយកិច្ចការពារនេះ ហើយដែលត្រូវបានចែងនៅក្នុងកថាវគ្គទី ១៣៨, ១៣៩ និង ១៤០ ក្នុង "ឯកសារស្តីពីលទ្ធផល" នៃកិច្ចប្រជុំកំពូល :

**ករណីយកិច្ចការពារប្រជាជនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ :**

កថាវគ្គទី ១៣៨ : រដ្ឋនីមួយៗមានករណីយកិច្ចការពារប្រជាជនរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ករណីយកិច្ចនេះរួមមានការទប់ស្កាត់ឧក្រិដ្ឋកម្មបែបនេះ រួមទាំងការញុះញង់ដែលនាំអោយមានឧក្រិដ្ឋកម្មទាំងនេះផង តាមរយៈមធ្យោបាយសមស្រប និងចាំបាច់ ។ យើងជារដ្ឋភាគីទទួលស្គាល់នូវករណីយកិច្ចនេះ ហើយនឹងមានវិធានការណ៍ស្របគ្នានោះ ។ តាមករណីចាំបាច់ សហគមន៍អន្តរជាតិនឹងជំរុញ និងជួយដល់រដ្ឋអោយអនុវត្តនូវករណីយកិច្ចនេះ និងជួយគាំទ្រដល់អង្គការសហប្រជាជាតិក្នុងការបង្កើតនូវវិធានការណ៍បឋមដើម្បីដោះស្រាយវិបត្តិនេះ (Early Warning) ។

កថាវគ្គទី ១៣៩ : តាមរយៈអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិក៏មានករណីយកិច្ចក្នុងការប្រើប្រាស់វិធានការណ៍សមស្របផ្នែកការទូត ផ្នែកមនុស្សធម៌ និងវិធានការណ៍បែបសន្តិវិធីផ្សេងៗទៀត ស្របទៅតាមជំពូកទី ៦ និងទី ៧ នៃធម្មនុញ្ញសហប្រជាជាតិ ដើម្បីជួយការពារប្រជាពលរដ្ឋពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ នៅក្នុងបរិបទនេះ យើងជារដ្ឋភាគីបានត្រៀមខ្លួនជាស្រេចដើម្បីចាត់វិធានការណ៍រួមអោយបានទាន់ពេលវេលា និងអោយបានម៉ឺងម៉ាត់ តាមរយៈក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិ ស្របទៅតាមធម្មនុញ្ញសហប្រជាជាតិ (រួមទាំងស្របតាមជំពូកទី៧) ទៅតាមករណីនីមួយៗ និងដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការប្រចាំតំបន់ដែលពាក់ព័ន្ធអោយបានសមស្រប ក្នុងករណីដែលវិធានការណ៍បែបសន្តិវិធីមិនមានជោគជ័យ និងក្នុងករណីដែលរដ្ឋខកខានមិនបានការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងសង្កត់ធ្ងន់ពីភាពចាំបាច់ដែលមហាសន្និបាតគួរបន្តការគិតគូរអំពីករណីយកិច្ចការពារប្រជាពលរដ្ឋពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់

ជាតិសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងផលវិបាកនៃអំពើទាំងនេះ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍នានានៃធម្មនុញ្ញ និងច្បាប់អន្តរជាតិ ។ តាមករណីចាំបាច់ និងសមស្រប យើងជារដ្ឋភាគីក៏មានការប្តេជ្ញាចិត្តក្នុងការជួយដល់រដ្ឋផ្សេងទៀតដើម្បីកសាងសមត្ថភាពរបស់គេ ក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំបាត់ជាតិសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជួយដល់រដ្ឋទាំងឡាយណាដែលប្រឈមការគំរាមកំហែង នៅមុនពេលដែលមានវិបត្តិ និងជំលោះកើតឡើងផងដែរ ។

កថាវគ្គទី ១៤០ : យើងជារដ្ឋភាគីគាំទ្រទាំងស្រុងនូវបេសកកម្មរបស់ទីប្រឹក្សាពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ លើការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។

នេះគឺជាការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិចំពោះករណីយកិច្ចការពារ ។ ជារួម សហគមន៍ពិភពលោកបានអះអាងថា : (ក) រដ្ឋនីមួយៗត្រូវការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ (ខ) សហគមន៍អន្តរជាតិត្រូវជួយដល់រដ្ឋទាំងអស់ក្នុងការបំពេញករណីយកិច្ចនេះ និង (គ) ប្រសិនបើរដ្ឋខកខានក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន នោះការការពារនោះនឹងក្លាយទៅជាការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ ។ ដើម្បីការពារប្រជាពលរដ្ឋ សហគមន៍អន្តរជាតិនឹងធ្វើការតាមរយៈអង្គការសហប្រជាជាតិ និងប្រើប្រាស់វិធានការណ៍បែបសន្តិវិធីនានា ដើម្បីជួយដល់រដ្ឋក្នុងការបំពេញករណីយកិច្ចការពាររបស់ខ្លួន ។ ប្រសិនបើវិធានការណ៍បែបសន្តិវិធីទាំងនោះមិនបានជោគជ័យទេ នោះនឹងមានវិធានការណ៍បែបយោធា (នៅក្នុងជំពូកទី៧ នៃធម្មនុញ្ញសហប្រជាជាតិមានចែងពីលទ្ធភាពរបស់អង្គការសហប្រជាជាតិក្នុងការប្រើប្រាស់កំលាំងយោធា) ។

## ៤. ការអនុវត្តន៍ករណីយកិច្ចការពារ

អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ គឺជាអ្នកគាំទ្រដ៏ខ្លាំងក្លាម្នាក់ចំពោះកម្មវិធីករណីយកិច្ចការពារនេះ ។ អ្នកស្នងតំណែងរបស់គាត់ គឺលោក បាន គីមូន ដែលចូលកាន់តំណែងជាអគ្គលេខាធិការអង្គការសហប្រជាជាតិនៅក្នុងខែមករា ឆ្នាំ ២០០៧ នោះ ក៏ជាអ្នកតស៊ូមតិដ៏ខ្លាំងក្លាអោយមានគោលការណ៍នេះផងដែរ ដោយគាត់បាននិយាយថា ភារកិច្ចបច្ចុប្បន្ននេះគឺត្រូវប្រែក្លាយករណីយកិច្ចការពារ "ពីពាក្យសំដីទៅជាសកម្មភាព" ។ ដើម្បីសំរេចនូវបេសកកម្មនេះលោក បាន គីមូន បានចេញរបាយការណ៍មួយនៅក្នុងខែមករា ឆ្នាំ ២០០៩ ដែលមានចំណងជើងថា*ការអនុវត្តន៍នូវករណីយកិច្ចការពារ* ។ របាយការណ៍នេះ គឺជាឯកសារលំអិតលើកដំបូងរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍នេះ ហើយនៅក្នុងនោះ លោកអគ្គលេខាធិការបានចង្អុលបង្ហាញពីផែនការរបស់គាត់ក្នុងការប្រែក្លាយគោលការណ៍នៃករណីយកិច្ចការពារនេះអោយទៅជាការអនុវត្តន៍ជាក់ស្តែង ។

នៅក្នុងរបាយការណ៍នេះ លោក បាន គីមូន បានបែងចែកករណីយកិច្ចការពារជា ៣ ផ្នែកសំខាន់ៗ រួមមាន :

១. ករណីយកិច្ចការពាររបស់រដ្ឋ

២. ជំនួយអន្តរជាតិ និងការកសាងសមត្ថភាព

៣. ការឆ្លើយតបអោយបានទាន់ពេលវេលា និងអោយបានម៉ឺងម៉ាត់ទៅនឹងវិបត្តិមនុស្សធម៌ ។

ផ្នែកទាំងបីនេះមានថាមភាពដូចគ្នា ហើយក៏មិនចាំបាច់មានលំដាប់លំដោយរឹងត្អឹងដែរ ព្រោះដើម្បីអោយវិធានការណ៍ឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬការបំបាត់ជាតិសាសន៍ ធ្វើឡើងបានទាន់ពេលវេលា និងមានភាពបត់បែន ។ ចំណុចសំខាន់នៃផ្នែកទាំងបីនេះ គឺសង្កត់ធ្ងន់ទៅលើការទប់ស្កាត់មិនអោយឧក្រិដ្ឋកម្មទាំងនេះក្លាយទៅជាអំពើឃោរឃៅកាន់តែធំឡើង ។

*ផ្នែកទីមួយ : ករណីយកិច្ចការពាររបស់រដ្ឋ*

ផ្នែកទីមួយបានសង្កត់ធ្ងន់ថា រដ្ឋនីមួយៗមានករណីយកិច្ចចំបងក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ នៅក្នុងរបាយការណ៍របស់គាត់ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានផ្តល់អនុសាសន៍អំពីរបៀបដែលត្រូវប្រកាន់ខ្ជាប់នូវករណីយកិច្ចនេះ ដូចតទៅ :

- ធានាថាមានយន្តការដែលមានប្រសិទ្ធិភាពដើម្បីដោះស្រាយទំនាស់ក្នុងប្រទេស ។
- ការពារសិទ្ធិរបស់ស្ត្រី យុវជន និងក្រុមជនភាគតិចនានានៅក្នុងរដ្ឋ ។
- អនុវត្តសន្ធិសញ្ញាច្បាប់អន្តរជាតិពាក់ព័ន្ធនានាស្តីពីសិទ្ធិមនុស្ស ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ស្តីពីជនភៀសខ្លួន ក៏ដូចជាលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។
- ប្រកាន់យកនូវដំណើរការស្វ័យឆ្លុះបញ្ចាំងដើម្បីស្វែងយល់ថាតើគោលការណ៍នៃករណីយកិច្ចការពារអាចត្រូវបញ្ចូលទៅក្នុងការអនុវត្តន៍របស់រដ្ឋដោយរបៀបណា ។
- កែលំអនូវលក្ខខ័ណ្ឌនានាដែលជួយជំរុញអោយមានការប្រកាន់ខ្ជាប់នូវករណីយកិច្ចការពារ ដូចជាធ្វើការជាមួយប៉ូលីស យោធា តុលាការ អ្នកតាក់តែងច្បាប់ ដើម្បីកែលំអនីតិរដ្ឋ និងការការពារសិទ្ធិមនុស្ស ។
- ធ្វើការជាមួយសង្គមស៊ីវិល និងអង្គការអន្តរជាតិដើម្បីសំរបសំរួលការអភិវឌ្ឍន៍ករណីយកិច្ចការពារ ។

*ផ្នែកទីពីរ : ជំនួយអន្តរជាតិ និងការកសាងសមត្ថភាព*

ផ្នែកទីពីរនិយាយអំពីការប្តេជ្ញាចិត្តរបស់សហគមន៍អន្តរជាតិក្នុងការផ្តល់ជំនួយដល់រដ្ឋនានា សំរាប់ការកសាងសមត្ថភាពរបស់ខ្លួន ក្នុងការការពារប្រជាពលរដ្ឋរបស់ពួកគេពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ ផ្នែកទីពីរក៏សង្កត់ធ្ងន់ផងដែរថា វាជាការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិ ក្នុងការជួយដល់រដ្ឋទាំងឡាយណា "ដែលប្រឈមនឹងការគំរាមកំហែងនៅមុនពេលដែលវិបត្តិ និងជំលោះកើតឡើង" ដែលជាថ្មីម្តងទៀតចំណុចនេះបញ្ជាក់ថា ការ

បង្ការគឺជាវិធីដ៏ល្អបំផុតដើម្បីបញ្ឈប់អំពើឃោរឃៅ ។ ក្នុងចំណោមសំណើជាច្រើនរបស់គាត់ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានផ្ដល់អនុសាសន៍ដូចខាងក្រោមសំរាប់រដ្ឋ :

- គាំទ្រអង្គការសហប្រជាជាតិ និងអង្គការថ្នាក់អនុតំបន់នានា ដែលមានយន្ដការសំរាប់ការពិភាក្សា ការអប់រំ និងការបណ្ដុះបណ្ដាលអំពីសិទ្ធិមនុស្ស និងបទដ្ឋានមនុស្សធម៌ ។
- លើកកំពស់ការរៀនសូត្រពីតំបន់មួយទៅតំបន់មួយអំពីករណីយកិច្ចការពារ រួមទាំងការអប់រំអំពីយុទ្ធសាស្ត្រ និងការអនុវត្តន៍ទាំងឡាយណាដែលសមស្របបំផុតដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗដទៃទៀត ។
- លើកទឹកចិត្តប្រទេសនានាអោយផ្ដល់ថវិកាដល់កម្មវិធីទាំងឡាយណាដែលនឹងកែលំអលក្ខខ័ណ្ឌសំរាប់ករណីយកិច្ចការពារ ដូចជា កំណែទំរង់យោធា និងការលើកកំពស់នីតិរដ្ឋជាដើម ។
- បង្កើតក្រុម "ឆ្លើយតបបន្ទាន់" ជាក្រុមស៊ីវិល និងយោធាថ្នាក់តំបន់ ដើម្បីជួយដល់រដ្ឋទាំងឡាយណាដែលមានជំលោះកាន់តែខ្លាំងឡើងៗ ។

*ផ្នែកទីបី : ការឆ្លើយតបអោយបានទាន់ពេលវេលា និងអោយបានម៉ឺងម៉ាត់*

ផ្នែកទីបីផ្ដោតទៅលើការទទួលខុសត្រូវរបស់សហគមន៍អន្ដរជាតិ ក្នុងការចាត់វិធានការណ៍អោយបានទាន់ពេលវេលា និងអោយបានម៉ឺងម៉ាត់ ដើម្បីទប់ស្កាត់និងបញ្ឈប់អំពើប្រល័យពូជសាសន៍ ការបំបាត់ជាតិសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅពេលដែលរដ្ឋខកខានក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន ។ លោក បាន គីមូន បានស្នើឡើងនូវជំហានមួយចំនួនសំរាប់អនុវត្តផ្នែកទីបីនេះ ហើយដែលអង្គការសហប្រជាជាតិ និងអង្គការថ្នាក់តំបន់ និងថ្នាក់អនុតំបន់នានា ត្រូវប្រកាន់យក ។ សំណើទាំងនេះរួមមាន:

- ក្រុមប្រឹក្សាសន្ដិសុខ និងមហាសន្និបាតរបស់អង្គការសហប្រជាជាតិ អាចចាត់តាំងអោយមានបេសកកម្មស្វែងរកការពិត ដើម្បីស៊ើបអង្កេត និងធ្វើរបាយការណ៍ស្ដីពីការចោទប្រកាន់ពីការរំលោភបំពានច្បាប់អន្ដរជាតិណាមួយ ។ ក្រុមប្រឹក្សាសិទ្ធិមនុស្សក៏អាចចាត់តាំងអោយមានបេសកកម្មដើម្បីស្វែង

រកការពិត និងចាត់តាំងតំណាងពិសេស ឬ "អ្នករាយការណ៍" ដើម្បីផ្តល់យោបល់អំពីស្ថានភាពណាមួយ ។

- បេសកកម្មទាំងនេះអាចផ្តល់នូវវិធានការណ៍បឋមអំពីវិបត្តិមនុស្សធម៌ និងអាចធ្វើការចរចារជាមួយនឹងមេដឹកនាំរដ្ឋដែលមានវិបត្តិនោះ ។
- កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងថ្នាក់សកល ដើម្បីធានាអោយមានកិច្ចសហការកាន់តែខ្លាំង និងកាន់តែមានប្រសិទ្ធិភាពរវាងអង្គការសហប្រជាជាតិ និងអង្គការថ្នាក់តំបន់ និងអនុតំបន់ រួមទាំងលើការចែករំលែកសមត្ថភាព និងសមត្ថភាពទាក់ទងនឹងវិធានការណ៍បឋមផង ។
- ការពិចារណារបស់អង្គការសហប្រជាជាតិក្នុងការរៀបចំវិធានការណ៍យោធាសំរាប់ "ការឆ្លើយតបបន្ទាន់"របស់អង្គការសហប្រជាជាតិ ទៅនឹងអំពើឃោរឃៅដែលបំរុងនឹងកើត និងអំពើឃោរឃៅដែលកំពុងកើតឡើងជាក់ស្តែង ។

ក្រៅពីផ្នែកទាំងបីនេះ របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិក៏បានសង្កត់ធ្ងន់ផងដែរទៅលើភាពចាំបាច់អោយមានការបង្កើនសមត្ថភាពផ្នែកវិធានការណ៍បឋម ។ លោកអគ្គលេខាធិកាអង្គការសហប្រជាជាតិបានអះអាងថា វិធានការណ៍បឋមគឺជាប្រការសំខាន់ណាស់សំរាប់គោលការណ៍នៃករណីយកិច្ចការពារ ជាពិសេសចំពោះជំលោះដែលនឹងកើតឡើង ដោយសារគោលបំណងចំបងគឺដើម្បីទប់ស្កាត់អំពើឃោរឃៅធំៗនៅមុនពេលដែលវាកើតឡើង ។

## ៥. សំណួរ-ចំលើយអំពីករណីយកិច្ចការពារ

*ហេតុអ្វីបានជាយើងត្រូវការអោយមានករណីយកិច្ចការពារ?*

សហគមន៍អន្តរជាតិបានខកខានម្តងហើយម្តងទៀត ក្នុងការការពារប្រជាពលរដ្ឋពីអំពើប្រល័យពូជ-សាសន៍ និងអំពើឃោរឃៅផ្សេងៗទៀត ដូចជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាដើម ។ ករណីយកិច្ចការពារ គឺជាគោលការណ៍មួយដែលបានកើតឡើងដើម្បីអោយរដ្ឋនីមួយៗ និងសហគមន៍អន្តរជាតិធ្វើនូវអ្វីៗ

គ្រប់យ៉ាងតាមដែលខ្លួនអាចធ្វើបានដើម្បីទប់ស្កាត់អំពើឃោរឃៅនៅពេលអនាគត ។ ស្ថាប័នអន្តរជាតិជាច្រើន ជាពិសេសអង្គការសហប្រជាជាតិត្រូវបានបង្កើតឡើងដើម្បីទប់ស្កាត់ជំលោះរវាងរដ្ឋនិងរដ្ឋ ។ ប៉ុន្តែចាប់តាំងពីពេលបញ្ចប់សង្គ្រាមត្រជាក់មក ជំលោះភាគច្រើនបានកើតឡើងនៅក្នុងរង្វង់រដ្ឋ ដូចជានៅប្រទេសសូម៉ាលី បូស្នី និងប្រទេសភូមាជាដើម ។

ករណីយកិច្ចការពារត្រូវបានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៥ ដែលក្នុងនោះសហគមន៍អន្តរជាតិបានសន្យាថានឹងការពារប្រជាពលរដ្ឋរបស់ខ្លួន ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ រដ្ឋជាសមាជិកបានឯកភាពគ្នាថា រដ្ឋនីមួយៗមានករណីយកិច្ចការពារប្រជាពលរដ្ឋរបស់ខ្លួន និងថាសហគមន៍អន្តរជាតិមានកាតព្វកិច្ចដើម្បីជួយដល់រដ្ឋនានាក្នុងការបំពេញនូវករណីយកិច្ចនេះ ។ នៅទីបញ្ចប់ ពួកគេបានព្រមព្រៀងថា ប្រសិនបើរដ្ឋណាមួយខកខានក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួននោះ វាជាភារកិច្ចរបស់សហគមន៍អន្តរជាតិក្នុងការធ្វើអន្តរាគមន៍តាមរយៈអង្គការសហប្រជាជាតិ ។

*តើអ្នកណាខ្លះដែលមានករណីយកិច្ចក្នុងការការពារ?*

ករណីយកិច្ចគឺជារបស់រដ្ឋនីមួយៗ ក៏ដូចជារបស់សហគមន៍អន្តរជាតិផងដែរ គឺតាមរយៈអង្គការសហប្រជាជាតិ ។ ជាមូលដ្ឋាន ករណីយកិច្ចការពារមានន័យថា រដ្ឋនីមួយៗមានកាតព្វកិច្ចការពារប្រជាពលរដ្ឋរបស់ខ្លួនពីអំពើឃោរឃៅធំៗ (រួមមានអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍) ។ តែទោះជាយ៉ាងណាក៏ដោយ ករណីយកិច្ចការពារក៏ជាកាតព្វកិច្ចរបស់រដ្ឋទាំងអស់ដែលជាសមាជិករបស់អង្គការសហប្រជាជាតិផងដែរ ក្នុងការជួយដល់រដ្ឋដទៃទៀត និងធ្វើអន្តរាគមន៍ ប្រសិនបើចាំបាច់ ដើម្បីការពារប្រជាពលរដ្ឋពីអំពើឃោរឃៅធំៗ ។

*តើ "ករណីយកិច្ចការពារ" គ្រាន់តែវាក្យស័ព្ទថ្មីដែលប្រើជំនួស "អន្តរាគមន៍មនុស្សធម៌" មែនឬ?*

គឺមិនមែនទេ ។ "អន្តរាគមន៍មនុស្សធម៌" គឺនិយាយអំពី "សិទ្ធិ" របស់រដ្ឋមួយក្នុងការចាត់វិធានការណ៍ទាំងបង្ខំចិត្ត ប្រឆាំងនឹងរដ្ឋមួយទៀតដើម្បីបញ្ឈប់អំពើឃោរឃៅ ។ ករណីយកិច្ចការពារគឺនិយាយអំពីករណីយកិច្ចរបស់រដ្ឋទាំងអស់ក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួន និងការទទួលខុសត្រូវរបស់សហគមន៍អន្តរជាតិក្នុងការជួយដល់រដ្ឋផ្សេងៗអោយបំពេញនូវករណីយកិច្ចការពារនេះ ។ ប្រសិនបើរដ្ឋណាមួយខកខានក្នុងការការពារប្រជាពលរដ្ឋរបស់ខ្លួននោះ វិធានការណ៍ជាច្រើន (រួមទាំងវិធានការណ៍ផ្នែកសេដ្ឋកិច្ច ការទូត និងនយោបាយ) នឹងត្រូវបានយកមកប្រើប្រាស់ដើម្បីជួយដល់រដ្ឋនោះ ហើយនៅក្នុងករណីដែលធ្ងន់ធ្ងរបំផុត នឹងមានការប្រើប្រាស់អន្តរាគមន៍ផ្នែកយោធាដើម្បីបញ្ឈប់អំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅធំៗដទៃទៀត (សូមមើលផ្នែកទី ៣ និង ៤ នៃឯកសារនេះ)។

*តើគោលការណ៍នៃករណីយកិច្ចការពារមានការប៉ះពាល់ទៅលើអធិបតេយ្យភាពរដ្ឋយ៉ាងណាដែរ?*

រដ្ឋបានទទួលស្គាល់តាំងពីយូរណាស់មកហើយ នូវដែនកំណត់នៃអ្វីដែលគេមានសិទ្ធិធ្វើបាន មិនថាចំពោះប្រជាពលរដ្ឋរបស់ខ្លួន ឬប្រជាពលរដ្ឋនៃរដ្ឋដទៃនោះទេ ។ ឧទាហរណ៍ សេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សចែងថា រដ្ឋត្រូវតែការពារសិទ្ធិបុគ្គលនិងសិទ្ធិសង្គម ។ អនុសញ្ញាក្រុងហ្សឺណែវ និងសិទ្ធិសញ្ញាជាច្រើនទៀត ដែលហាមឃាត់ការធ្វើទារុណកម្ម ការជួញដូរមនុស្ស ឬការរីកសាយនៃអាវុធនុយក្លេអែរ ក៏បានកំណត់ពីដែនសិទ្ធិរបស់រដ្ឋក្នុងការប្រព្រឹត្តនូវអ្វីដែលពួកគេចង់ធ្វើនោះផងដែរ ។ ជាមួយគ្នានេះដែរ ក៏មានការផ្លាស់ប្តូរនូវការយល់ឃើញពីបញ្ហាអធិបតេយ្យភាពរដ្ឋនេះផងដែរ ។ ការផ្លាស់ប្តូរនេះកើតមានឡើង ដោយសារមានការគាំទ្រសិទ្ធិមនុស្សកាន់តែខ្លាំង និងជាប្រតិកម្មទៅនឹងអំពើឃោរឃៅដែលរដ្ឋាភិបាលបានប្រព្រឹត្តចំពោះប្រជាពលរដ្ឋស៊ីវិលរបស់ខ្លួន ។ ដូច្នេះហើយ អត្ថន័យនៃពាក្យអធិបតេយ្យភាពរដ្ឋ បានប្តូរពីការដែលរដ្ឋមានសិទ្ធិធ្វើនូវអ្វីៗគ្រប់យ៉ាងដែលខ្លួនចង់ធ្វើនៅក្នុងរង្វង់ព្រំដែននៃប្រទេសរបស់ខ្លួន ទៅជាកាតព្វកិច្ចរបស់រដ្ឋចំពោះប្រជាពលរដ្ឋស៊ីវិលរបស់ខ្លួនវិញ ។ ទស្សនទានថ្មីនេះគឺជារបស់លោក Francis Deng ដែលថា "អធិបតេយ្យភាពរដ្ឋគឺជាករណីយកិច្ច" (សូមមើលផ្នែកទី ១ នៃឯកសារ

នេះ)។ ករណីយកិច្ចក្នុងការការពារប្រជាពលរដ្ឋពីអំពើប្រល័យពូជសាសន៍ និងការរំលោភបំពានក្នុងទំរង់ផ្សេងៗទៀតគឺជាករណីយកិច្ចសំខាន់បំផុតរបស់រដ្ឋ។ និយាយអោយសាមញ្ញ : គឺយកប្រជាពលរដ្ឋជាចំបង ។

*តើកម្មវិធីករណីយកិច្ចការពារនេះមានគោលបំណងបញ្ឈប់អ្វីខ្លះ?*

នៅក្នុងកិច្ចប្រជុំកំពូលពិភពលោករបស់អង្គការសហប្រជាជាតិនៅឆ្នាំ ២០០៥ មេដឹកនាំលើពិភពលោកបានព្រមព្រៀងគ្នាថា ករណីយកិច្ចការពារគ្របដណ្តប់ដល់ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរចំនួន ៤ : អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ ។ ដូច្នេះហើយ ករណីយកិច្ចការពារមិនរាប់បញ្ចូលនូវការគំរាមគំហែងផ្សេងៗទៀតទៅលើសន្តិសុខមនុស្ស ដូចជាការប្រែប្រួលអាកាសធាតុ មេរោគអេដស៍/ជំងឺអេដស៍ ឬគ្រោះមហន្តរាយឡើយ ។ ករណីយកិច្ច ការពារមិនមែនមានន័យថា ជាការដោះស្រាយនូវការគំរាមគំហែងគ្រប់យ៉ាងទៅលើមនុស្សនោះទេ គឺជាការដោះស្រាយតែចំពោះអំពើដែលធ្ងន់ធ្ងរបំផុតនៃការរំលោភបំពានប្រឆាំងនឹងករណីយកិច្ចការពារប៉ុណ្ណោះ ។

*តើឧក្រិដ្ឋកម្មទាំងបួននេះគឺជាអ្វី?*

*អំពើប្រល័យពូជសាសន៍* ត្រូវបានកំណត់និយមន័យដោយអង្គការសហប្រជាជាតិថា គឺជាអំពើទាំងឡាយណាដែលត្រូវបានធ្វើឡើង "ដោយមានគោលបំណងបំផ្លាញក្រុមជាតិពន្ធ ជាតិសាសន៍ សញ្ជាតិ ក្រុមសាសនាណាមួយទាំងមូល ឬមួយផ្នែក" ។ អំពើទាំងនោះរួមមានការសំលាប់សមាជិកក្រុម បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សមាជិកក្រុម និងការបំបែកកុមារចេញពីក្រុមនោះ ។ *ឧក្រិដ្ឋកម្មសង្គ្រាម* រួមមានអំពើទាំងឡាយណាដែលបានប្រព្រឹត្តឡើងក្នុងពេលមានសង្គ្រាម ឬជំលោះ ដូចជាការធ្វើទារុណកម្ម ការចាប់ជំរិត ការប្រព្រឹត្តមិនគប្បីចំពោះអ្នកទោសសង្គ្រាម ការវាយប្រហារសំដៅទៅរកប្រជាជនស៊ីវិលក្នុងអំឡុងពេលប្រយុទ្ធ ការរំលោភសេពសន្ថវៈ ទាសភាពផ្លូវភេទ និងការបង្អត់អាហារ ជាដើម ។ *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ* រួមមាន ារកាប់សំលាប់ ការបង្ខំអោយមានទាសភាព ការនិរទេស ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើទាំងឡាយណាដែល "បណ្តាលអោយមានការឈឺចាប់យ៉ាងធំធេង ឬបណ្តាលអោយរងរបួសយ៉ាងធ្ងន់ធ្ងរដល់រាងកាយ ការធ្វើអោយរងគ្រោះផ្លូវកាយ ឬផ្លូវចិត្ត" ។ អំពើបែបនេះច្រើនតែត្រូវបានប្រព្រឹត្តនៅ

ពេលមានជំលោះ ប៉ុន្តែក៏អាចប្រព្រឹត្តឡើងដោយរបបណាមួយដែលព្យាយាមគាបសង្កត់ប្រជាជនផងដែរ ។ ចំពោះពាក្យ *ការបំបាត់ជាតិសាសន៍* មានន័យថាគឺជាការបណ្តេញចេញ ឬការជំលៀសប្រជាជនចេញដោយបង្ខំ ដោយការបណ្តេញមនុស្សចេញ ឬដោយការបំភិតបំភ័យតាមរយៈការសំលាប់ ភេរវកម្ម ការរំលោភសេពសន្ថវៈ ។ល។ សំរាប់ព័ត៌មានបន្ថែមអំពីឧក្រិដ្ឋកម្មទាំងនេះ សូមមើលលក្ខន្តិកៈក្រុងរ៉ូមស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលមានការពន្យល់យ៉ាងលំអិតអំពីឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលមានវិបសាយ (http://www.un.org/law/icc/index.html និង http://untreaty.un.org/cod/icc/statute/romefra.htm)

*តើអាចប្រែក្លាយករណីយកិច្ចការពារពីគោលការណ៍ទៅជាសកម្មភាពដោយរបៀបណា?*

មនុស្សនៅទូទាំងសកលលោកកំពុងខិតខំដើម្បីគាំទ្រករណីយកិច្ចការពារ ។ អង្គការសហប្រជាជាតិបានប្តេជ្ញាចិត្តថានឹងអនុវត្តគោលការណ៍នេះ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំបាត់ជាតិសាសន៍ មិនអោយកើតឡើងសាជាថ្មីឡើយ ។ រហូតមកដល់បច្ចុប្បន្ននេះ មានអង្គការសង្គមស៊ីវិល និងស្ថាប័នអប់រំជាច្រើន នៅក្នុងតំបន់ផ្សេងគ្នានៃពិភពលោកកំពុងធ្វើការដើម្បីអនុវត្តករណីយកិច្ចការពារនេះ ។ អង្គការ និងស្ថាប័នទាំងនេះរួមមាន :

- មជ្ឈមណ្ឌលដើម្បីករណីយកិច្ចការពារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (The Asia-Pacific Centre for the Responsibility to Protect) ដែលមានការិយាល័យនៅក្នុងសកលវិទ្យាល័យគ្វីនស្លែន ទីក្រុងប្រីសបាន ប្រទេសអូស្ត្រាលី (www.r2pasiapacific.org)
- សម្ព័ន្ធភាពអន្តរជាតិដើម្បីករណីយកិច្ចការពារ (The International Coalition for the Responsibility to Protect) ដែលមានការិយាល័យនៅទីក្រុងញូវយ៉ក (www.responsibilitytoprotect.org)
- មជ្ឈមណ្ឌលសកលដើម្បីករណីយកិច្ចការពារ (The Global Centre for the Responsibility to Protect) ដែលមានការិយាល័យនៅទីក្រុង ញូវយ៉ក សហរដ្ឋអាមេរិកដែរ (http://globalr2p.org)

ក្រៅពីអង្គការទាំងនេះបានខិតខំដើម្បីអនុវត្តករណីយកិច្ចការពារនោះ ក៏នៅមានអង្គការដៃគូជាច្រើនទៀតផងដែរ រួមមាន៖

- អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ដែលមានការិយាល័យកណ្ដាលនៅទីក្រុងញូវយ៉ក ប៉ុន្តែក៏មានការិយាល័យនៅជុំវិញពិភពលោកផងដែរ (www.hrw.org) ។
- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលការថែរក្សាសន្តិភាពរបស់កូហ្វី អាណាន់ (The Kofi Annan international Peacekeeping Training Centre) នៅទីក្រុងអាក្រា ប្រទេសហ្គាណា (www.kaiptc.org) ។
- អុកស្វាមអន្តរជាតិ (Oxfam International) ដែលមានការិយាល័យនៅអុក្សហ្វឹត ចក្រភពអង់គ្លេស ប៉ុន្តែក៏មានការិយាល័យជុំវិញពិភពលោកផងដែរ (www.oxfam.org) ។

ក្នុងការអនុវត្តករណីយកិច្ចការពារ មជ្ឈមណ្ឌលដើម្បីករណីយកិច្ចការពារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក បានបោះពុម្ពផ្សាយឯកសារមួយចំនួនដែលផ្ដល់នូវព័ត៌មានបន្ថែមទៀតដែលមាននៅក្នុងវិបសាយ

(http://www.r2pasiapacific.org/index.php?option=com_content&task=view&id=13&Itemid=66).

ឯកសារមួយចំនួនដែលចេញផ្សាយនាពេលថ្មីនេះ រួមមាន៖

- 'Protecting Civilians in Uncivil Wars' (http://www.r2pasiapacific.org/documents.protecting_civilians_in_uncivil_wars.pdf)
- 'Preventing Genocide and Mass Atrocities: Causes and Paths of Escalation' (http://www.r2pasiapacific.org/images/stories/food/preventing%20genocide%20and%20mass%20atrocities%20-%20causes%20and%20paths%20of%20escalation.pdf)
- 'The Responsibility to Protect in Southeast Asia' (http://www.r2pasiapacific.org/images/stories/food/r2p%20in%20southeast%20asia.pdf)

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងមជ្ឈមណ្ឌលដើម្បីករណីយកិច្ចការពារប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (The Asia-Pacific Centre for the Responsibility to Protect) តាមរយៈវិបសាយ www.r2pasiapacific.org